# កញ្ឆក់ចេញពីទ្វារនរក

## Snached from the corridors of hell



## រឿងរ៉ាវ

## នៃជីវិតដែលផ្លាស់ប្រែ

*The story of a transformed life*

# អារម្ភកថា

*ខ្ញុំបានគិតអស់រយៈពេលជាយូរ មុននឹងសម្រេចចិត្តសរសេររឿងរ៉ាវរបស់ខ្ញុំ។ ដោយហេតុផលសាមញ្ញៗដែលនាំខ្ញុំទៅកាន់អតីតកាល ហើយដែលខ្ញុំចង់បំភ្លេចចោល តែនៅទីបំផុត ខ្ញុំដឹងថា ខ្ញុំមិនអាចលាក់ទុកបទពិសោធន៍នៅក្នុងជីវិតរបស់ខ្ញុំ ដែលមិនធ្លាប់មាន និងអស្ចារ្យបែបនេះសម្រាប់ខ្លួនឯងបានឡើយ ដូច្នេះហើយបានជាខ្ញុំត្រូវតែចែកចាយ ដើម្បីជួយដល់អស់អ្នកដែលកំពុងជួបប្រទះទុក្ខលំបាកដ៏ជូរចត់។*

*បទពិសោធន៍របស់ខ្ញុំ ត្រូវតែបានជាប្រយោជន៍ដល់អ្នកដទៃ។ ទោះយ៉ាងណា ខ្ញុំមិនបាននិយាយលម្អិតអំពីជីវិតរបស់ខ្ញុំទេ ព្រោះមានការខ្វះដែលធ្វើឲ្យខ្ញុំពិបាកក្នុងការពណ៌នា និងអាចធ្វើឲ្យគោលបំណងនៃសៀវភៅនេះ ធ្វើឲ្យអ្នកមានសង្ឃឹមបែរជាអស់សង្ឃឹមវិញ។ ខ្ញុំជឿច្បាស់ថា ក្រោយពីការអានអត្ថបទទាំងនេះរួចហើយ ប្រសិនបើលោកអ្នកពិតជាចង់ឲ្យមានការផ្លាស់ប្ដូរក្នុងជីវិតលោកអ្នក ចូររំពឹងគិតអំពីអ្វីមួយដែលអស្ចារ្យនឹងកើតឡើង អំពីការកើតជាថ្មី អំពីជីវិតថ្មី និងអំពីការចាប់ផ្ដើមថ្មី។*

"*សូមរីករាយអានដោយមេត្រី!*"

**បកប្រែដោយលោកគ្រូ ម៉ៅ អាន និងក្រុមការងារមជ្ឈមណ្ឌលសម្ព័ន្ធមេត្រីកម្ពុជា**

Translated by Pastor Mao An & Nexus Centre Cambodia Team

# កញ្ឆក់ចេញពីទ្វារនរក

តាមរយៈប៉ុន្មានទំព័រនេះ ខ្ញុំចង់ចែកចាយអំពីអ្វីដែលជាជីវិតរបស់ខ្ញុំកាលពីមុន រហូតដល់ពេលខ្ញុំរកឃើញសេចក្តីពិតនៅទីបំផុត និងអត្ថន័យពិតនៃជីវិត។ ការសម្លឹងទៅកាន់អតីតកាល មិនងាយស្រួលទេ ជាពិសេស ពេលដែលឆ្លងកាត់ទុក្ខសោក និងការឈឺចាប់ ប៉ុន្តែថ្មីៗនេះ ខ្ញុំជឿយ៉ាងច្បាស់ថា ខ្ញុំត្រូវតែធ្វើបន្ទាល់ និងបង្ហាញពីចិត្តកតញ្ញូដល់ព្រះមួយអង្គ ដែលបានសង់ជីវិតរបស់ខ្ញុំឡើងវិញ។

ប៉ុន្តែ តើមាននរណាម្នាក់ ឬអ្វីមួយ ដែលពិតជាអាចសង់ឡើងវិញបាននូវជីវិតមួយ ដែលបានធ្លាក់ចុះដុនដាប គ្មានសង្ឃឹម គ្មាននរណាអាចជួយបាន ហើយនៅពេលដែលទុក្ខព្រួយរបស់លោកអ្នកបែបនេះ នោះលោកអ្នកលែងចង់បានអ្វីទាំងអស់ គឺរង់ចាំថ្ងៃស្លាប់ ដើម្បីឲ្យបានរួចនៅទីបំផុតឬទេ?

ជាញឹកញាប់ ខ្ញុំបានសួរខ្លួនឯងថា ហេតុអ្វីបានជាខ្ញុំកើតលើលោកនេះ តើអ្វីទៅជាគោលបំណងដែលខ្ញុំមានរូបនៅលើផែនដី ពេញដោយទុក្ខព្រួយដូច្នេះ!! ចាប់តាំងពីថ្ងៃដែលខ្ញុំកើតមក ខ្ញុំជួបតែការបាក់ទឹកចិត្ត និងបរាជ័យ យល់មិនដល់ គិតមិនឃើញសោះ។

មានពាក្យពោលថា: យើងកើតមកមានផ្កាយលាភ មានផ្កាយគ្រោះ។ សម្រាប់ខ្ញុំវិញ ខ្ញុំបានរកឃើញចម្លើយយ៉ាងរហ័ស។ ខ្ញុំកើតមក ស្ថិតក្រោមផ្កាយគ្រោះទាំងស្រុង។

ម្តាយខ្ញុំក៏ដូចជាស្ត្រីឯទៀតៗដែរ គាត់បានគិតថា គាត់បានជួបជាមួយនឹងបុរសគ្រប់លក្ខណ៍ ដែលនឹងរង់ចាំជួយសម្រាលដៃជើងរបស់គាត់ ជាអ្នកដែលមានវត្តមានជាញឹកញាប់ កម្រនឹងខកខាន ហើយត្រឡប់មកផ្ទះវិញ មានទាំងបាច់ផ្កាមកជាមួយ។

ប៉ុន្តែ ការពិតខុសឆ្ងាយខ្លាំងណាស់ ហើយម្តាយខ្ញុំបានដឹងភ្លាមៗថា ឪពុកខ្ញុំជាមនុស្សម្នាក់មួម៉ៅច្រើន ហើយឆេវឆាវបំផុត ដែលធ្វើឲ្យពិបាកខ្លាំងឡើងៗក្នុងការរស់នៅជាមួយគាត់។

ជីវិតនៅផ្ទះតានតឹង និងគ្មានសុកមង្គលសោះ ហើយអ្វីៗមិនបានប្រសើរឡើងតាមពេលវេលាសោះ ពីមួយថ្ងៃទៅមួយថ្ងៃ ពីមួយខែទៅមួយខែ ជម្លោះក្នុងគ្រួសារបានកើតឡើង អំពើហិង្សាក្លាយជាទម្លាប់រស់នៅប្រចាំថ្ងៃ។

ពួកយើងពិបាកក្នុងការមានពេលសុខសាន្ត និងអំណរ ហើយការពិត គ្រួសាររបស់យើងបានហែកហួរខ្លួនឯងជាបំណែក ដែលអាចមើលឃើញតាមរយៈទឹកមុខរបស់ពួកយើង គឺមិនសូវមានស្នាមញញឹមទេ។ ទឹកភ្នែកហូរកាត់ថ្ពាល់ជាញឹកញាប់។

ជាច្រើនឆ្នាំក្រោយពីហេតុការណ៍ទាំងអស់នេះមក អតីតកាលរបស់ខ្ញុំនៅតែដក់ជាប់ក្នុងគំនិតរបស់ខ្ញុំ ទោះបីជាពេលនោះ ខ្ញុំជាក្មេងប្រុស ទើបតែមានអាយុបួនឬប្រាំឆ្នាំក៏ដោយ។

ខ្ញុំនៅតែមានការចងចាំហេតុការណ៍ទាំងនោះនៅក្នុងគំនិតជានិច្ច ព្រោះនៅពេលដែលក្មេងប្រុសម្នាក់ទទួលរងការវាយដំ ហើយមើលឃើញម្តាយរបស់ខ្លួនទទួលការរំលោភបំពាន រូបភាពទាំងអស់នេះមិនអាចលុបបាត់ពីគំនិតរបស់គេឡើយពេញមួយជីវិតរបស់គេ ហើយម្តងបន្តិចៗ នាំគេទៅរកភាពក្រៀមក្រំដោយសារការប៉ះទង្គិចផ្លូវចិត្តជាច្រើន និងភាពគ្មានសណ្តាប់ធ្នាប់ផ្សេងៗទៀត។

កាលមានអាយុប្រាំពីរឆ្នាំ នោះជាពេលដែលខ្ញុំជួបទុក្ខលំបាកខ្លាំងបំផុត គ្រានោះក្នុងជីវិតរបស់ខ្ញុំ ខ្ញុំបានដាក់ចំណងជើងថា "**នៅទ្វារទីមួយនៃស្ថាននរក**"។

ប្រសិនបើខ្ញុំបានធ្វើខុស ដោយសារការដើរបង្ហួសឪពុករបស់ខ្ញុំ នៅពេលដែលគាត់កំពុងមួម៉ៅ នោះគាត់ច្បាស់ជាវាយធ្វើបាបខ្ញុំភ្លាមៗ។ ខ្ញុំមិនដែលបានសុខឡើយ ខ្ញុំតែងសួរខ្លួនឯងថា ធ្វើដូចម្តេចឲ្យខ្ញុំអាចជិតស្និទ្ធជាមួយគាត់បាន ធ្វើដូច

*ម្តេចឲ្យខ្ញុំអាចនិយាយលេងជាមួយគាត់បាន តើជាពេលត្រឹមត្រូវដែរឬអត់... ខ្ញុំតែងស្ថិតនៅក្រោមសម្ពាធ ហើយវាមានឥទ្ធិពលអាក្រក់ដល់ខ្ញុំ។ ពីមួយថ្ងៃទៅមួយថ្ងៃ ខ្ញុំត្រឡប់ជាក្មេងប្រុសដែលគ្មានទំនាក់ទំនង ខឹងច្រើន និងមិនដែលល្ហែល្ហើយសោះ។*

*ខ្ញុំតែងនឹកចាំមិនភ្លេចពីថ្ងៃដែលឪពុករបស់ខ្ញុំ គាត់ខឹងយ៉ាងខ្លាំង គាត់បានបោចសក់របស់ខ្ញុំ បានញ៉ឹងខ្ញុំឡើងផុតពីដី ហើយបានគ្រវែងខ្ញុំចោល ដូចជាក្រណាត់ជូតជើង។ ទឹកភ្នែកបានហូរកាត់ថ្ពាល់របស់ខ្ញុំ ខ្ញុំរន្ធត់យ៉ាងខ្លាំង ហើយក្នុងពេលជាមួយគ្នានោះ ក៏ពេញដោយសេចក្តីសម្អប់ដូចគ្នា... ប្រមុះរបស់ខ្ញុំបែក* **ហើយខ្ញុំមិនអាចកើយក្បាលលើខ្នើយបានទេ** *ពីព្រោះឈឺចាប់ ដោយសារតែការជាំឈាម។ នៅថ្ងៃនោះ ខ្ញុំបានសម្លឹងមើលឪពុកខ្ញុំចំភ្នែក ប៉ុន្តែនៅតែភ័យញ័រ ខ្ញុំបានប្រាប់គាត់ថា៖ "ប៉ា ស្តាប់ឲ្យច្បាស់ ខ្ញុំស្បថថា នៅពេលខ្ញុំអាយុ១៨ឆ្នាំ ខ្ញុំនឹងសម្លាប់ប៉ា"។*

*ពាក្យសម្តីដែលខ្ញុំបាននិយាយទាំងនោះបានលងខ្ញុំជាប់ ចាប់តាំងពីថ្ងៃនោះមក។ ជាច្រើនឆ្នាំកន្លងទៅ គ្មានអ្វីប្រែប្រួលសោះ។ ហិង្សា នៅតែបន្តជាហិង្សាដដែល។ លុះដល់ពេលមួយ ម្តាយរបស់ខ្ញុំបានរត់ចេញពីផ្ទះជាមួយកូនបីនាក់ ដែលមានអាយុ៤ឆ្នាំ ៨ឆ្នាំ និង៩ឆ្នាំ ហើយធ្វើឲ្យពេលវេលាដំបូងនៃទុក្ខលំបាក ឈានដល់ទីបញ្ចប់។*

*ប៉ុន្តែ ក្រោយមក ខ្ញុំត្រូវជួបលំបាកនឹងរកអាហារដាក់ចាន។ ម្តាយរបស់ខ្ញុំធ្វើជាស្ត្រីបោសសម្អាតបានតែពីរបីម៉ោងប៉ុណ្ណោះក្នុងមួយសប្តាហ៍ៗ ហើយពួកយើងបានរស់នៅក្រតោកយ៉ាក ដោយគ្មានអ្វីបរិភោគជាញឹកញាប់។ ខ្ញុំត្រូវធ្វើការច្រើនម៉ោង ទោះបីជានៅក្មេង ទើបតែអាយុត្រឹម១១ ទៅ១២ឆ្នាំក៏ដោយ ដើម្បីរកលុយចូលផ្ទះ។*

*ជំនួសឲ្យការទាំងអស់នោះ ហើយជំនួសឲ្យការលំបាកដែលខ្ញុំបានឆ្លងកាត់ ខ្ញុំបានក្លាយជាអ្នកប្រយុទ្ធ ហើយចង់បានជោគជ័យ។ ពេលវេលាទាំងនោះ មិន*

ងាយស្រួលទេ ពេញទៅដោយទុក្ខលំបាក និងទឹកភ្នែក ប៉ុន្តែការទាំងអស់នោះបានសំលៀងខ្ញុំ និងបានធ្វើឲ្យខ្ញុំក្លាយជាក្មេងប្រុសក្លាហានម្នាក់ ដែលមិនខ្លាចធ្វើការនឿយហត់ ដើម្បីផ្គត់ផ្គង់សេចក្តីត្រូវការក្នុងគ្រួសាររបស់ខ្ញុំ ។

នៅពេលដែលខ្ញុំធំគ្រប់អាយុ ខ្ញុំបានសម្រេចចិត្តធ្វើជាមនុស្សម្នាក់ដែលសំខាន់។ ខ្ញុំត្រូវគេជួលឲ្យធ្វើជាបុគ្គលិកផ្នែកលក់ នៅក្នុងអាគារដ៏សំខាន់មួយ គឺជាក្រុមហ៊ុនបំពាក់ឧបករណ៍សុវត្ថិភាព។ ជារឿយៗ ខ្ញុំបានក្លាយបុគ្គលឆ្នើមបំផុតក្នុងចំណោមពួកគេ ខ្ញុំទទួលបានជោគជ័យយ៉ាងត្រចះត្រចង់ ធ្វើឲ្យប្រាក់ខែរបស់ខ្ញុំកើនឡើងខ្ពស់បំផុតនៅពេលនោះ។ ខ្ញុំបានឈ្នះការក្រកួតបុគ្គលិកផ្នែកលក់ទាំងអស់ នៅក្នុងផ្នែករបស់ខ្ញុំខាងសកម្មភាព ដែលបានអនុញ្ញាតឲ្យខ្ញុំធ្វើដំណើរជុំវិញពិភពលោក ហើយខ្ញុំបានស្គាល់ប្រទេសស្អាតៗជាច្រើន មានដូចជា ប្រទេសម៉ូរ៉ូក (Morocco) ស៊ុយអែត (Switzerland) អេស្ប៉ាញ (Spain) នឹងក្រិក (Grece)។

នេះជាពេលវេលាលំដាប់ថ្នាក់លេខមួយ។ អ្វីៗហាក់ដូចជាប្រសើរឡើង និងកាន់តែប្រសើរឡើងៗ ជាប់រហូត។ ខ្ញុំបានមានអារម្មណ៍ថាមានសុភមង្គលណាស់។

ទោះបីជាមានការទាំងអស់នោះហើយក្តី ខ្ញុំមិនដែលស្កប់ចិត្តជាមួយនឹងអ្វីៗដែលខ្ញុំមាននោះទេ។ ទុក្ខវេទនារបស់ក្មេងដែលត្រូវរំលោភបំពាន ភាពអសន្តិសុខនិងភាពទ័លក្រដែលខ្ញុំបានជួបពីអតីតកាល បានបង្ខំឲ្យខ្ញុំចេះតែចង់បានថែមទៀតជាប់ជានិច្ច ហើយមិនចេះចប់... ខ្ញុំបានសម្រេចចិត្តបង្កើតក្រុមហ៊ុនមួយចំនួន ។

ក្នុងភាពជាដៃគូ ខ្ញុំបានរកស៊ីជួលវីដេអូយ៉ាងជោគជ័យ។ ហាងនោះចំណេញណាស់ ហើយនាំលុយចូលយ៉ាងច្រើន ប៉ុន្តែ នៅតែមិនគ្រប់គ្រាន់សម្រាប់ខ្ញុំ។ ខ្ញុំបានបង្កើតក្រុមហ៊ុនអចលនទ្រព្យមួយ ដែលចម្រើនឡើងជាប្រចាំ ហើយលុយហូរចូល។ បន្ទាប់មក ខ្ញុំបានបង្កើតក្រុមហ៊ុនប្រមូលទិញលោហៈមានតម្លៃ និងមាសដែលប្រើរួច ហើយលក់លោហៈទាំងនោះទៅឲ្យរោងចក្រកែច្នៃ។ ខ្ញុំទុកឲ្យលោកអ្នកស្រមៃមើលចុះ ថាតើជំនួញទាំងនេះរកលុយបានច្រើនប៉ុនណា។

ប្រាក់ចំណូលរបស់ខ្ញុំច្រើនណាស់នៅថ្ងៃនោះ ហើយខ្ញុំខ្មាសមិនហ៊ានប្រាប់លោកអ្នកថា ខ្ញុំរកលុយបានច្រើនប៉ុនណាទេនៅពេលនោះ។

តាមរយៈក្រុមហ៊ុនទាំងនេះ ខ្ញុំបានសង់អាណាចក្រមួយពិតប្រាកដសម្រាប់ខ្លួនឯង ហើយនៅទីបំផុត ខ្ញុំបានក្លាយជាមនុស្សម្នាក់ដែលសំខាន់នៅក្នុងពិភពមុខជំនួញ។

ហេតុនេះហើយ បានជាអាយុទើបតែ២០ឆ្នាំជាង់ប៉ុណ្ណោះ ខ្ញុំអាចមានអ្វីៗដែលខ្ញុំចង់បាន។

ខ្ញុំមានឡានស្អាត ផ្ទះធំដែលមានអាងហែលទឹក មានទូកឯកជន និងអ្វីៗច្រើនទៀត។ ខ្ញុំបានចេញទៅក្រៅច្រើន ជះលុយ ដើម្បីឲ្យជីវិតសប្បាយ។

ដោយការឆ្វេសប្រហែសក្មេងខ្លួន ខ្ញុំបានលិចលង់សន្សឹមៗទៅក្នុង "**ទ្វារទីពីរនៃស្ថាននរក**"។ លោកអ្នកដឹងច្បាស់ណាស់ថា នៅពេលដែលលោកអ្នកមានលុយច្រើន លោកអ្នកមានមិត្តភក្តិច្រើន ហើយជីវិតរបស់ខ្ញុំរស់នៅរហូតដល់ពេញហូរហៀរ។ ក្រោយមក ខ្ញុំបានចាប់ផ្តើមពាក់ព័ន្ធជាមួយនឹងពិភពលោកគួរខ្លាចនេះ ដែលខ្ញុំមិនចង់ឲ្យនរណាម្នាក់ចូលរួម ឬសូម្បីតែស្គាល់ផង។

លុយរបស់ខ្ញុំ កិត្តិយសរបស់ខ្ញុំ ការស្រេកឃ្លានសុភមង្គលរបស់ខ្ញុំ និងការចេញទៅក្រៅយ៉ាងច្រើនរបស់ខ្ញុំ ជាហេតុនាំឲ្យខ្ញុំបានជួបមនុស្សជាច្រើន ប៉ុន្តែតើជាមនុស្សប្រភេទណា!

ការរាប់អានមិត្តភិក្ករបស់ខ្ញុំ កើតចេញពីពេស្យាចារ និងការរួមភេទដូចគ្នា។ ខ្ញុំបានចេញទៅក្រៅជាមួយក្មេងប្រុស ក្មេងស្រីដែលរកស៊ីផ្លូវភេទ ហើយខ្ញុំបានសេពថ្នាំញៀន។

គ្រឿងស្រវឹងបានហូរជាប់ជានិច្ច ពីធីជប់លៀងរបស់យើងធ្វើឡើងជាប់ជាច្រើន

ថ្ងៃ ហើយខ្ញុំបានគិតក្នុងចិត្តថា វិធីនេះនឹងធ្វើឲ្យខ្ញុំបានសប្បាយជាប់រហូត ហើយចន្លោះប្រហោងដែលនៅក្នុងចិត្តរបស់ខ្ញុំនឹងបានពេញ។

ខ្ញុំត្រឡប់មកផ្ទះវិញដោយអស់កម្លាំង ទាំងមានបំណងមួយគត់ គឺចង់ជប់លៀងទៀត ដើម្បីបំភ្លេចទុក្ខព្រួយ និងការខ្វល់ខ្វាយក្នុងជីវិតរបស់ខ្ញុំ។ ការធ្លាក់ចូលទៅក្នុងទ្វារស្ថាននរក បានចាប់ផ្តើមហើយ...

ខ្ញុំចាំបានថា នៅយប់មួយ យើងមានពិធីជប់លៀងនៅក្នុងវត្តសាល គ្រឿងស្រវឹង និងគ្រឿងញៀនស្ថិតនៅកន្លែងលំដាប់លេខមួយ។ រំពេចនោះ មនុស្សកកកុញនៅចំណតខាងក្រៅ ។ ខ្ញុំក៏ចេញទៅមើល ឃើញមនុស្សម្នាក់ដែលកំពុងដេកនៅលើដី ហើយអ្នកនោះគឺជាមិត្តភក្តិរបស់ខ្ញុំ ។ គាត់បានចាក់ថ្នាំហេរ៉ូអ៊ីនខ្លួនឯង ហើយបានប្រើលើសកម្រិត។ គាត់បានប្រកាច់នៅទីនោះ ហើយយើងមិនអាចជួយអ្វីគាត់បានទេ។ គាត់បានស្លាប់នៅចំពោះភ្នែករបស់ខ្ញុំ ទាំងឈឺចាប់បំផុត។

ក្រោយពីហេតុការណ៍ដែលទើបតែបានកើតឡើងនេះ ខ្ញុំមានអារម្មណ៍មិនល្អសោះ ហើយតានតឹងចិត្តជាខ្លាំង។ ខ្ញុំលែងសាកល្បងអ្វីៗតទៅទៀតហើយ។ ទោះបីជាខ្ញុំមានអ្វីៗដែលខ្ញុំចង់បានក៏ដោយ ក៏ចិត្តរបស់ខ្ញុំនៅតែព្រួយ និងនៅទទេ។ ខ្ញុំមានអារម្មណ៍ឯកកោ ហើយមានភាពទទេ គ្មានអ្វីសោះនៅក្នុងខ្ញុំ។ តើលោកអ្នកដែលមានអារម្មណ៍ ដូចជាលោកអ្នកកំពុងបើកបរនៅលើផ្លូវមួយដ៏វែងឆ្ងាយ ហើយលោកអ្នកបើកបរទៅ បើកបរទៅ ទាំងមិនដឹងថា លោកអ្នកកំពុងបើកបរទៅទីណាឬទេ?

ស្ថានភាពបែបនេះ បានបន្តអស់រយៈពេលជាច្រើនឆ្នាំ ហើយខ្ញុំមិនដែលទទួលបានពេលវេលាដែលប្រកបដោយសុភមង្គលពិតប្រាកដទេ ប៉ុន្តែ បានត្រឹមតែអារម្មណ៍រីករាយមួយភ្លែតប៉ុណ្ណោះ។ ជានិច្ចកាល ខ្ញុំស្វែងរកអ្វីដែលថ្មី អ្វីដែលផ្តល់អត្ថន័យដល់ជីវិតរបស់ខ្ញុំ។ ខ្ញុំជឿថា ខ្ញុំបានរកឃើញវានៅទីបំផុត គឺនៅពេលដែលខ្ញុំបានជួបនឹងមិត្តស្រីរបស់ខ្ញុំ ដែលខ្ញុំបានមានកូនស្រីជាមួយនាង ដោយដាក់ឈ្មោះថា "វ៉ាណេសា្សា" ប៉ុន្តែ ខ្ញុំបែរជាមានអារម្មណ៍ថាស្រងាកចិត្តយ៉ាងឆាប់

បំផុត។

ខ្ញុំបានគិតថា ខ្ញុំបានសង់ជម្រកកក់ក្តៅមួយសម្រាប់ខ្លួនឯង ដាក់ន្ទែងដែលខ្ញុំអាចរីករាយ ហើយនៅពេលដែលខ្ញុំត្រឡប់ពីធ្វើការមកផ្ទះ ខ្ញុំអាចធ្វើជាឪពុកដ៏ល្អម្នាក់ ជាដៃគូគួរឲ្យស្រឡាញ់ម្នាក់ ទោះបីជានៅខាងក្រោយការទាំងអស់នេះ បានបង្កប់នូវការយល់ច្រឡំយ៉ាងជ្រាលជ្រៅ និងការមិនសប្បាយចិត្តក៏ដោយ។ ខ្ញុំនៅតែរស់នៅក្នុងជីវិតមិនពិតប្រាកដ រាប់រកមនុស្សដែលធ្លាប់ស្គាល់ និងមិត្តកក្តិមកពីពិភពងងឹត។

អ្វីដែលមិនធ្វើឲ្យខ្ញុំភ្ញាក់ផ្អើល គឺនៅពេលដែលមិត្តស្រីរបស់ខ្ញុំបានប្រាប់ខ្ញុំ នៅល្ងាចមួយ ក្នុងខែធ្នូ ឆ្នាំ១៩៩១ ថា នាងត្រូវបែកពីខ្ញុំទៅរកបុរសម្នាក់ទៀត... នោះជាអ្វីដែលកើតឡើងជៀសមិនផុត...

ពីរបីសប្តាហ៍ក្រោយមក នាងបានចាកចេញពិតមែន ហើយខ្ញុំត្រូវប្រឈមមុខនឹងទុក្ខវេទនានេះមួយផ្សេងទៀត ហាក់បីដូចជាជីវិតរបស់ខ្ញុំបានល្បងលមិនទាន់គ្រប់គ្រាន់ និងហាក់បីដូចជាខ្ញុំរងទុក្ខមិនទាន់ដល់កម្រិត។

ប៉ុន្មានថ្ងៃក្រោយពីការបែកគ្នានេះមក គឺជាពេលវេលានៃទុក្ខព្រួយ និងភាពកណ្តោចកណ្តែងយ៉ាងជ្រាលជ្រៅ។

បន្ទាប់មកទៀត ដូចលោកអ្នកនឹងបានអានខាងក្រោមនេះ អាណាចក្រដែលខ្ញុំបានសង់ដោយខ្លួនឯង បានដួលរលំ ដូចជាផ្ទះដែលធ្វើពីសន្លឹកបៀរ!!

ជំនួញដំបូងដែលត្រូវការឲ្យខ្ញុំចូលហ៊ុនកាលនៅគ្រាលំបាក ហើយខ្ញុំបានចូលហ៊ុនច្រើនបំផុត បានជ្រើសរើសដកភាគហ៊ុន ហើយនោះជាជំហានដំបូងក្នុងចំណោមព្រឹត្តិការណ៍ផ្សេងៗដែលផ្លាស់ប្តូរអ្វីៗជាច្រើននៅក្នុងជីវិតរបស់ខ្ញុំ។

នៅពេលជាមួយគ្នានោះ ក្រុមហ៊ុនអចលនទ្រព្យក៏មានលទ្ធផលអាក្រក់ ដូច្នេះ ខ្ញុំត្រូវលក់ក្រុមហ៊ុននេះដោយមិនបានទទួលអ្វីទាំងអស់ ដើម្បីជៀសវាងការក្ស័យធន ហើយជំនួញទីបី ដែលជាមុខរបរប្រមូលទិញមាស និងលោហៈមានតម្លៃ

ដែលខ្ញុំបានចូលហ៊ុនមួយចំណែកធំជាមួយនឹងម្ចាស់ភាគហ៊ុន ត្រូវបានបិទ នៅពេលដែលម្ចាស់ភាគហ៊ុនធំត្រូវចាប់ខ្លួនពីបទកេងបន្លំមូលនិធិ និងចាត់ចែងទ្រព្យសម្បត្តិក្រុមហ៊ុនមិនត្រឹមត្រូវ។ គាត់បានហោះទៅក្រៅប្រទេស ហើយអ្វីៗបានឈប់ទាំងអស់។

ពេលនោះ ខ្ញុំដឹងខ្លួនថា ខ្ញុំបានបាត់បង់អ្វីៗទាំងអស់ដែលខ្ញុំមាន។ ខ្ញុំហិនហោច គ្មានអ្វីនៅសល់ទេ ប៉ុន្តែ ដូចដែលខ្ញុំបានរៀបរាប់ពីរបីបន្ទាត់នៅខាងលើរួចហើយ គឺជំនួសឲ្យស្ថានភាពដែលហិនហោច ហើយនឹកស្មានមិនដល់ គឺមានអ្វីមួយកំពុងកក្រើកនៅក្នុងខ្ញុំ អ្វីៗបានកើតឡើងនៅក្នុងភាពអស្ចារ្យ និងនៅក្នុងរបៀបមួយ ដែលនឹកស្មានមិនដល់។

ល្ងាចមួយ ខ្ញុំមានចិត្តវិលវល់តែម្នាក់ឯង នៅរានហាលផ្ទះរបស់ខ្ញុំ ដោយការថប់បារម្ភ និងទុក្ខព្រួយ ទឹកភ្នែកហូរកាត់ថ្ពាល់ខ្ញុំ គឺខ្ញុំបានប្រឈមមុខនឹងភាពគ្មានអ្វីសោះជាលើកដំបូង។ ខ្ញុំមិនអាចឈប់យំបានទេ ជីវិតរបស់ខ្ញុំទាំងមូល បានកន្លងផុតទៅនៅចំពោះភ្នែករបស់ខ្ញុំ ហើយខ្ញុំដឹងច្បាស់ថា ថ្ងៃចុងក្រោយរបស់ខ្ញុំបានមកដល់ហើយ ពីព្រោះខ្ញុំបានសម្រេចចិត្តបញ្ចប់វា។ គ្មានន័យអ្វីទៀតទេ ហើយក៏គ្មានតម្លៃនឹងបន្តទៀតដែរ។

ជីវិតរបស់ខ្ញុំពោពេញដោយភាពងងឹតយ៉ាងក្រាស់ ខ្ញុំមិនអាចរកឃើញច្រកចេញបានឡើយ។ ខ្ញុំហិនហោចអស់ហើយ អស់សង្ឃឹមរលីង គឺដូចជាមានជញ្ជាំងមួយឈរនៅចំពីមុខខ្ញុំ ជាជញ្ជាំងយ៉ាងខ្ពស់ ដែលមិនអាចឲ្យខ្ញុំមើលឃើញពន្លឺបាន។

ខ្ញុំបានសម្លឹងមើលមេឃ ហើយស្រែកអស់ពីសំឡេងថា ព្រះអើយ ប្រសិនបើព្រះអង្គមានមែន ទូលបង្គំសូមឲ្យព្រះអង្គធ្វើអ្វីមួយសម្រាប់ទូលបង្គំ សូមមេត្តាជួយទូលបង្គំផង បើមិនអញ្ចឹងទេ ទូលបង្គំមានតែលោតចុះពីលើអាគារនេះឲ្យស្លាប់ប៉ុណ្ណោះ សូមទ្រង់មេត្តា សូមទ្រង់មេត្តាផង! ហើយអស់ពេលយ៉ាងយូរ ខ្ញុំបានបន្តស្រែកដដែលៗឲ្យទ្រង់ធ្វើអ្វីមួយសម្រាប់ខ្ញុំ គឺខ្ញុំស្រែកអង្វរព្រះអង្គ...។ គ្មានអ្វីអាចឲ្យខ្ញុំស្បើយក្នុងចិត្តបានឡើយ ហើយខ្ញុំក៏មិនអាចរស់នៅទាំងឈឺចាប់បែប

*នេះបានទៀតដែរ។ ខ្ញុំកំពុងមានសេចក្ដីវេទនា ហើយខ្ញុំត្រូវតែសម្រេចចិត្តបញ្ចប់អ្វីៗទាំងអស់។*

*ភ្លាមនោះ ខ្ញុំក៏មានអារម្មណ៍ថា សេចក្ដីសុខសាន្តដ៏ជ្រាលជ្រៅកំពុងបំពេញខ្ញុំ។ ទឹកភ្នែករបស់ខ្ញុំឈប់ហូរ ហើយខ្ញុំបានដឹងថា ព្រះពិតជាស្ដាប់ខ្ញុំមែន។ ខ្ញុំមានអារម្មណ៍យ៉ាងអស្ចារ្យ ដែលពិបាកនឹងពន្យល់ ដែលមានអ្វីមួយទើបនឹងកើតឡើង។ ខ្ញុំមានអារម្មណ៍ស្រាល ហាក់បីដូចជាខ្ញុំទទួលបានដំណឹងល្អ ហើយក្រោយពីគំនិតរបស់ខ្ញុំបានសុខស្រួល ខ្ញុំក៏ដំណេក។*

*ចាប់ពីពេលនោះមក ជីវិតរបស់ខ្ញុំបានផ្លាស់ប្ដូរ គឺមានអ្វីមួយបានកើតឡើងដល់ខ្ញុំ។ សម្រាប់ខ្ញុំ ហាក់ដូចជាការទួញយំរៀបរាប់របស់ខ្ញុំអំពីទុក្ខលំបាក បានប៉ះពាល់ព្រះហឫទ័យព្រះ ហើយអ្វីដែលខ្ញុំនឹងប្រាប់លោកអ្នកនៅពេលនេះ នឹងធ្វើឲ្យលោកអ្នកភ្ញាក់ផ្អើលជាពុំខាន ហើយលោកអ្នកមុខជាយល់ថាជារឿងដែលពិបាកនឹងជឿ ការទីមួយដែលខ្ញុំបានទទួលបទពិសោធន៍ គឺមានចិត្តសុខសាន្ត ទោះបីជាខ្ញុំកំពុងប្រឈមមុខនឹងកាលៈទេសៈអាក្រក់ក៏ដោយ តែខ្ញុំបានសុខសាន្ត គឺខ្ញុំមានចិត្តសុខសាន្ត។*

*ក្រោយមកមិនយូរប៉ុន្មាន ខ្ញុំបាននិយាយទូរស័ព្ទទៅកាន់សមាជិកមួយចំនួននៅក្នុងគ្រួសាររបស់ខ្ញុំ ដែលរស់នៅឯញូខាលិនដូនីយ៉ា* (New Caledonia)*។ ពួកគេបានស្ដាប់ឮពីពេលវេលាទុក្ខលំបាក ដែលខ្ញុំបានឆ្លងកាត់។ ពួកគេបានទទូចឲ្យខ្ញុំចំណាយពេលណាមួយជាមួយពួកគេ ។ ក្រោយមក ខ្ញុំបានចំណាយពេលពីបីខែជាមួយពួកគេ។*

*គេបានរៀបចំខ្ទមស្លឹកមួយសម្រាប់ខ្ញុំនៅក្រុងឌុមបៀ* (Dumbea) *(ជាក្រុងតូចមួយមានចម្ងាយពីរបីគីឡូម៉ែត្រពីរដ្ឋធានី)។ ខ្ញុំក៏ចូលស្នាក់នៅទីនោះ។ ជឿខ្ញុំចុះ ពិតជាមានភាពខុសប្លែកគ្នាទៅនឹងភាពប្រណិតដែលខ្ញុំធ្លាប់មាន។* ***គ្មានបង្គន់ គ្មានទឹកផ្កាឈូក ហើយអ្វីៗគ្រប់យ៉ាងនៅកណ្ដាលវាលទាំងអស់!!***

ខ្ញុំធ្លាប់រស់នៅក្នុងអាគារប្រណិត ក្នុងតំបន់ឆើតឆាយនៃក្រុងពើគីញ៉ាន នៅភាគខាងត្បូងនៃប្រទេសបារាំង ខ្ញុំមានរថយន្តស្អាត ខ្ញុំមានលុយដែលមិនដឹងថាត្រូវចាយយ៉ាងម៉េចអស់ ខ្ញុំធ្លាប់ជាម្ចាស់ក្រុមហ៊ុន និងធ្លាប់ជាម្ចាស់ភាគហ៊ុន ប៉ុន្តែឥឡូវនេះ ខ្ញុំត្រូវរស់នៅក្នុងខ្ទមស្ទឹក ដែលគ្មានរបស់ទំនើប នៅកណ្ដាលតំបន់ចុងកាត់មាត់ញក (*niaoulis* និង *bois-de-fer*) ជាតំបន់ព្រៃរបស់ញូខាលិនដូនីយ៉ា (New Caledonia)។

ប៉ុន្តែ ខ្ញុំបានសម្របតាម ហើយទទួលយកស្ថានភាពនេះ ព្រោះគ្មានអ្វីអាក្រក់ជាងអ្វីដែលខ្ញុំធ្លាប់ស្គាល់រួចមកហើយនោះឡើយ។

ជាញឹកញាប់ ខ្ញុំទៅតាមដងទន្លេ ចម្ងាយប្រហែល៣០ម៉ែត្រពីកន្លែងខ្ញុំនៅ ហើយសម្លឹងមើលមេឃ ទាំងពោលថា:

សូមព្រះជាម្ចាស់ដឹកនាំ ហើយបំផ្លាស់បំប្រែទូលបង្គំ ហើយលើសនេះ សូមផ្ដុំជីវិតទូលបង្គំឡើងវិញផង។

អ្វីៗចាប់ផ្ដើមមានការផ្លាស់ប្រែ។ ខ្ញុំបានទៅព្រះវិហារ ហើយបានជួបគ្រិស្តបរិស័ទជាច្រើនដែលមើលទៅ ឃើញទឹកមុខគេប្រកបដោយភាពសប្បាយរីករាយ។ មានអារម្មណ៍ពេញដោយសេចក្ដីសុខសាន្តនៅទីនោះ ហើយខ្ញុំមានអារម្មណ៍ល្អ ប៉ុន្តែ ខ្ញុំនៅតែជាទាសករនៃការជាច្រើន ខ្ញុំនៅជក់បារី ពីទៅបីកញ្ចប់ក្នុងមួយថ្ងៃ ហើយនៅមានរបួសចិត្តយ៉ាងធ្ងន់ធ្ងរ ដែលបណ្ដាលមកអតីតកាល ដែលអន្តរាយរបស់ខ្ញុំ។ ប៉ុន្តែ ព្រះជាម្ចាស់បានធ្វើការចំពោះចិត្តរបស់ខ្ញុំ ពីមួយថ្ងៃទៅមួយថ្ងៃ។

**បន្ទាប់មក ខ្ញុំបានសុំការអត់ទោសចំពោះព្រះអង្គ** តែមួយអង្គគត់ ដែលអាចអត់ទោសបាន ព្រះអង្គដែលបានប្រទានព្រះជន្មទ្រង់ផ្ទាល់ ដោយមិនស្ទាក់ស្ទើរ ដើម្បីសង្គ្រោះជីវិតខ្ញុំ។ ខ្ញុំកំពុងនិយាយអំពីព្រះយេស៊ូ ជាព្រះសង្គ្រោះរបស់ខ្ញុំ ដែលខ្ញុំបានចុះចូលនៅចំពោះព្រះអង្គ ដោយព្រោះព្រះអង្គជាព្រះ ដូចដែលខ្ញុំកំពុងសរសេរទីបន្ទាល់នេះ គឺព្រះអង្គបានផ្លាស់ប្រែខ្ញុំ ហើយបានរៀបចំជីវិត

របស់ខ្ញុំឡើងវិញ។ ព្រះអង្គបានរំដោះខ្ញុំ ឲ្យរួចពីអំណាចញៀនទាំងអស់ ដែលបានឃុំខ្ញុំជាប់ជាអ្នកទោស ហើយខ្ញុំអាចនិយាយបានថា ព្រះអង្គបានកញ្ចក់ខ្ញុំចេញពីស្ថាននរក ដែលខ្ញុំបានធ្លោះទៅ។

ថ្ងៃនេះ ដោយព្រោះការជួបប្រទះដ៏ស្រស់ត្រកាលជាមួយព្រះយេស៊ូនេះ ខ្ញុំបានរួចទាំងស្រុងពីច្រវាក់ ដែលបានទាញខ្ញុំទៅរកសេចក្តីស្លាប់។

## "ព្រះជាម្ចាស់បានប្រទានអ្វីៗដែលខ្ញុំបានបាត់បង់ត្រឡប់មកវិញ"

ព្រះជាម្ចាស់បានប្រទានអត្ថន័យថ្មីមួយដល់ជីវិតរបស់ខ្ញុំ។ ព្រះអង្គបានប្រទានឲ្យខ្ញុំមានភរិយាដ៏អស្ចារ្យម្នាក់ ដែលមានកូនស្រីពីរនាក់ផ្សេងទៀតនៅជាមួយ។

ខ្ញុំបានរស់នៅក្នុងក្រុងញូខាលិនដូនីយ៉ា (New Caledonia) អស់២០ឆ្នាំហើយឥឡូវនេះ ហើយខ្ញុំបម្រើព្រះនៅក្នុងក្រុមជំនុំរបស់ខ្ញុំ។ ប៉ុន្តែ ខ្ញុំមានការប្តូរផ្តាច់មួយទៀត ដែលត្រូវឆ្លើយតប។ ព្រះជាម្ចាស់បានត្រាស់ហៅខ្ញុំឲ្យធ្វើបន្ទាល់អំពីអ្វីៗ ដែលព្រះអង្គបានធ្វើសម្រាប់ខ្ញុំ ហើយប្រកាសអំពីការទាំងនោះគ្រប់ទីកន្លែង និងគ្រប់ពេលវេលា។

អ្វីដែលខ្ញុំបានសេរសេរ ឆ្លុះបញ្ចាំងតែមួយផ្នែកអំពីអ្វីដែលខ្ញុំបានឆ្លងកាត់តែប៉ុណ្ណោះ ពីព្រោះសេចក្តីវេទនាដែលខ្ញុំបានជួបប្រទះ នោះគួរឲ្យខ្លាច ប៉ុន្តែព្រះជាម្ចាស់បានធ្វើច្រើនសន្ធឹកសម្រាប់ខ្ញុំ ព្រះអង្គបានការពារខ្ញុំពីសេចក្តីស្លាប់អស់កល្បជានិច្ច។

នៅឆ្នាំ ២០០៨ ខ្ញុំបានធ្វើដំណើរជុំវិញប្រទេសបារាំង ខ្ញុំបានទៅលេងឪពុករបស់ខ្ញុំ ដែលខ្ញុំបានគម្រាមសម្លាប់ កាលពីខ្ញុំមានអាយុទើបតែ៧ឆ្នាំ។ តើលោកអ្នកនៅចាំទេ? ផ្ទុយទៅវិញ នៅពេលដែលខ្ញុំបានជួបគាត់ ខ្ញុំបានឱបថើបគាត់ ហើយបានអត់ទោសឲ្យគាត់គ្រប់យ៉ាង។ ឥឡូវនេះ យើងបានទាក់ទងគ្នា ហើយខ្ញុំគ្មានគំនុំ ឬកំហឹងណាមួយចំពោះគាត់សោះឡើយ។ ផ្ទុយទៅវិញ ខ្ញុំស្រឡាញ់គាត់

*ទោះបីជាខ្ញុំនៅតែនឹកឃើញអំពីទុក្ខវេទនាទាំងអស់ក៏ដោយ។*

## មានតែព្រះជាម្ចាស់ប៉ុណ្ណោះ ដែលអាចធ្វើឲ្យមានការផ្លាស់ប្រែបែបនេះ

*ព្រះអង្គបានផ្លាស់ប្រែភាពស្អប់ខ្ពើមរបស់ខ្ញុំ ឲ្យទៅជាសេចក្តីស្រឡាញ់ដ៏ពិត។ តើអ្នកណាអាចទាយដឹងពីការប្រែប្រួលនៃព្រឹត្តការណ៍ដែលខ្ញុំបានឆ្លងកាត់? ប៉ុន្តែខ្ញុំដឹងយ៉ាងប្រាកដថា ប្រសិនបើខ្ញុំមិនបានទទួលព្រះយេស៊ូនៅក្នុងជីវិតរបស់ខ្ញុំទេនៅថ្ងៃនេះ លោកអ្នកដែលនៅទីនេះនឹងមិនបានអានរឿងរ៉ាវរបស់ខ្ញុំឡើយ ព្រោះជីវិតធ្ងន់ទ្រមិនរួចសម្រាប់ខ្ញុំ មានសម្ពាធ និងអយុត្តិធម៌ច្រើនពេក ហើយខ្ញុំចង់តែបញ្ចប់ជីវិតបែបនោះ។*

*ឥឡូវនេះ ខ្ញុំចង់បង្ហាញដល់អស់អ្នកដែលអានរឿងរ៉ាវរបស់ខ្ញុំ ជាពិសេស អស់អ្នកដែលកំពុងឆ្លងកាត់ទុក្ខវេទនាជ្រាលជ្រៅ អស់អ្នកដែលកណ្តោចកណ្តែងបំផុត អស់អ្នកដែលមានអារម្មណ៍ថា សេចក្តីស្លាប់កំពុងចូលមកសន្សឹមៗ អ្នកអស់ដែលបានជាប់ចំណង ដោយអំពើអបាយមុខក្នុងប្រការណាមួយថា* ***លោកអ្នកមិនអាចចាកចេញពីការទាំងអស់នោះដោយខ្លួនឯងបានទេ*** *ដូចដែលគម្ពីរចែងនៅក្នុងអេភេសូរ ៦:១២ ថា* ***"ដ្បិតយើងរាល់គ្នាមិនតយុទ្ធនឹងសាច់ឈាមទេ គឺនិងពួកគ្រប់គ្រង ពួកមានអំណាច នឹងពួកម្ចាស់នៃសេចក្តីងងឹតនៅលោកិយនេះវិញ ហើយទាស់នឹងអំណាចអាក្រក់ខាងវិញ្ញាណនៅស្ថានដ៏ខ្ពស់ដែរ"។***

*ប្រសិនបើយើងមិនឲ្យព្រះធ្វើជាម្ចាស់លើយើង នោះយើងនឹងគ្មានកម្លាំង ឬទឹកចិត្តអាចតយុទ្ធនឹងពួកម្ចាស់នៃសេចក្តីងងឹតបានទេ ហើយសេចក្តីស្លាប់ខាងរូបកាយ និងខាងវិញ្ញាណកំពុងតែរង់ចាំយើង។*

*ប៉ុន្តែ ប្រសិនបើយើងបែរទៅរកព្រះជាម្ចាស់ដោយស្មោះត្រង់ សូមឲ្យព្រះអង្គដឹកនាំលោកអ្នក បង្ហាញផ្លូវលោកអ្នក ទទួលយកជីវិតលោកអ្នកមកក្នុងព្រះហស្ត ដោះលោកអ្នកឲ្យបានរួចពីអ្វីៗដែលលោកអ្នកជាប់ជាទាសករ ពេលនោះលោកអ្នកអាចជឿច្បាស់ថា ព្រះហស្តរបស់ព្រះជាម្ចាស់ នឹងបើកចំហសម្រាប់*

លោកអ្នក ហើយព្រះហស្តរបស់ព្រះអង្គ នឹងចាប់លោកអ្នកចេញ ហើយដោះលោកអ្នកឲ្យបានរួច។ កុំអស់សង្ឃឹម អ្វីដែលបានធ្វើឲ្យស្ថាននរកក្តោបក្តាប់ជីវិតលោកអ្នក នឹងក្លាយទៅជ័យជម្នះរបស់ព្រះ មកលើជីវិតរបស់លោកអ្នក។

ឥឡូវនេះ ខ្ញុំចង់និយាយទៅកាន់លោកអ្នកដែលកំពុងរងទុក្ខវេទនា ដោយព្រោះជំងឺរោគា។ ដូចគ្នានេះដែរ សូមលោកអ្នកត្រូវថ្វាយជីវិតរបស់លោកអ្នកចំពោះព្រះជាម្ចាស់ទៅ។ មែនហើយ យើងគ្រប់គ្រងអនាគតរបស់យើងមិនបានទេ ហើយនៅថ្ងៃណាមួយ យើងនឹងចាកចេញពីផែនដីនេះទៅ ព្រោះយើងកំពុងតែធ្វងកាត់ប៉ុណ្ណោះ ហើយយើងត្រូវទទួលយកសេចក្តីពិតនេះ តែព្រះជាម្ចាស់បានប្រទានសេចក្តីសន្យាដល់យើង ហើយប្រសិនបើពេលវេលារបស់លោកអ្នកមិនទាន់មកដល់នៅឡើយ លោកអ្នកត្រូវតោងឲ្យជាប់តាមព្រះបន្ទូល ដែលព្រះជាម្ចាស់បានមានបន្ទូលនៅក្នុង **អេសាយ ៥៣:៤-៥ "ទ្រង់បានទ្រាំទ្រ រងអស់ទាំងសេចក្តីឈឺចាប់របស់យើង ហើយបានផ្ទុកអស់ទាំងសេចក្តីទុក្ខព្រួយរបស់យើងជាពិត ប៉ុន្តែ យើងរាល់គ្នាបានរាប់ទ្រង់ទុកជាអ្នកមានទោសវិញ គឺជាអ្នកដែលព្រះបានវាយ ជាអ្នកដែលរងទុក្ខវេទនា"។** នេះជាសេចក្តីពិតដែលព្រះជាម្ចាស់បានដោះស្រាយជំងឺរោគារបស់យើង។

ហើយមានបទគម្ពីរមួយទៀតផងដែរ គឺ: **ទំនុកដម្កើង ១០៣:១-៦**

**"១ ឱព្រលឹងអញអើយ ចូរសរសើរដល់ព្រះយេហូវ៉ា ហើយគ្រប់ទាំងអស់ដែលរួមនៅក្នុងខ្លួនអញ ចូរសរសើរដល់ព្រះនាមបរិសុទ្ធនៃទ្រង់ដែរ ២ ព្រលឹងអញអើយ ចូរសរសើរដល់ព្រះយេហូវ៉ាចុះ ហើយកុំឲ្យភ្លេចបណ្តាព្រះគុណណាមួយរបស់ទ្រង់ឡើយ ៣ ដែលទ្រង់អត់ទោសចំពោះអស់ទាំងការទុច្ចរិតរបស់ឯង ទ្រង់ប្រោសជំងឺទាំងប៉ុន្មានរបស់ឯងឲ្យជា ៤ ក៏ជួយជីវិតឯងឲ្យរួចពីរណ្តៅ ហើយយកសេចក្តីសប្បុរស និងសេចក្តីមេត្តាករុណា បំពាក់ជាមកុដឲ្យឯងវិញ ៥ ព្រមទាំងប្រោសប្រទានឲ្យសំបកកាយនៃឯង បានស្កប់ស្កល់ដោយរបស់ល្អ ប្រយោជន៍ឲ្យវ័យក្មេងឯង បានកែឡើងជាថ្មី ដូចជាឥន្ទ្រី ៦ ព្រះយេហូវ៉ាទ្រង់សំរេចកិច្ចការដ៏សុចរិត**

***ហើយនឹងសេចក្តីយុត្តិធម៌ ចំពោះអស់អ្នកណាដែលត្រូវគេសង្កត់សង្កិន។"***

*សូមយាងព្រះយេស៊ូមកប្រោសរូបកាយរបស់លោកអ្នក ហើយរំដោះលោកអ្នកឲ្យបានរួចពីជំងឺនេះចុះ។ ចូរជឿលើសេចក្តីសន្យានេះ ដោយទុកចិត្តថា ដោយព្រោះមានសេចក្តីសន្យាទាំងនេះ នោះលោកអ្នកអាចមានបន្ទាល់យ៉ាងពិតប្រាកដនៅក្នុងជីវិត។ ចូរគ្រាន់តែរង់ចាំឲ្យព្រះជាម្ចាស់សម្រេចកិច្ចការរបស់ព្រះអង្គ ដូចដែលបានចែងទុកថា "**រង់ចាំសេចក្តីសង្គ្រោះរបស់ព្រះយេហូវ៉ា ឥតបារម្ភព្រួយ នោះល្អហើយ**"សាស្តា ៣:២៦។*

*ខ្ញុំអាចប្រាប់លោកអ្នកបានអំពីការនេះដោយចិត្តជឿជាក់ ព្រោះខ្ញុំបានទទួលបទពិសោធន៍នៃការប្រោសឲ្យជាដ៏អស្ចារ្យជាច្រើនដងនៅក្នុងជីវិតរបស់ខ្ញុំ។ ហើយខ្ញុំចង់បញ្ចប់សៀវភៅនេះ ដោយចែកចាយទីបន្ទាល់នេះឯង។*

*នៅឆ្នាំ ២០០៥ ខ្ញុំមានជំងឺជាទម្ងន់។ ខ្ញុំមានជំងឺឈឺក្បាលយ៉ាងខ្លាំង ខ្ញុំបានដេកនៅលើគ្រែជាច្រើនថ្ងៃ ក្រោកមិនរួចសោះ។ ខ្ញុំអស់កម្លាំង ហើយឈឺចុកចាប់យ៉ាងខ្លាំងនៅក្នុងខួរក្បាល ធ្វើឲ្យខ្ញុំមិនអាចបើកភ្នែករួច ដោយព្រោះតែពន្លឺបានចាំងភ្នែកខ្ញុំពេក ហើយធ្វើឲ្យខ្ញុំកាន់តែឈឺចុកចាប់ថែមទៀត។ ខ្ញុំមិនបានបរិភោគអ្វីសោះអស់រយៈពេលជាច្រើនថ្ងៃ។*

*ខ្ញុំចាប់ផ្តើមបាត់ការចងចាំ ខ្ញុំមិនអាចចងចាំអ្វីៗដែលខ្ញុំបានឆ្លងកាត់ឡើយ ខ្ញុំវិលវល់ ហើយកាន់តែពិបាកក្នុងការនិយាយស្តី។ កូនស្រីច្បងរបស់ខ្ញុំបានហៅវេជ្ជបណ្ឌិតប្រចាំគ្រួសាររបស់យើង ដែលគាត់តែងតែមកពិនិត្យខ្ញុំភ្លាមៗ។ គាត់បានសង្ស័យថាមានដុះសាច់ក្នុងខួរក្បាល ហើយគាត់ក៏បានបញ្ជូនខ្ញុំទៅកាន់មន្ទីរពេទ្យភ្លាម ហើយនៅទីនោះ ខ្ញុំបានឆ្លងកាត់ការត្រួតពិនិត្យជាច្រើន (ធ្លុះ សុងចោះ។ល។)។*

*ច្រើនម៉ោងក្រោយមក វេជ្ជបណ្ឌិតបានចូលមកក្នុងពេលដែលប្រពន្ធខ្ញុំកំពុងតែនៅក្បែរខ្ញុំ ហើយគាត់បានប្រាប់ពីលទ្ធផលធ្វើរោគវិនិច្ឆ័យគឺ"រលាកស្រោមខួរ"។*

គាត់ចង់ប្រាប់ខ្ញុំជាចំហ ហើយបានប្រាប់ខ្ញុំថា ជំងឺនេះធ្ងន់ធ្ងរណាស់ ហើយគាត់នឹងចេញវិជ្ជបញ្ជាឲ្យប្រើថ្នាំផ្សះខ្លាំងៗ សម្រាប់រយៈពេល ១៥ថ្ងៃ។ គាត់មិនអាចផ្តល់ការគិតទុកជាមុនរបស់គាត់បានទេ ហើយបានប្រកាសថា វាអាចមានផលអាក្រក់ក៏ថាបាន។

មុននឹងរកឃើញថ្នាំប្រឆាំងមេរោគ ជំងឺរលាកស្រោមខួរ ជាជំងឺមួយប្រភេទដែលអាចបណ្តាលឲ្យស្លាប់ ៧០% ហើយអស់អ្នកដែលបានរួចរស់មានជីវិត នឹងត្រូវទទួលរងជំងឺសរសៃប្រសាតយ៉ាងធ្ងន់ធ្ងរ។

ជានិច្ចកាល ប្រពន្ធខ្ញុំ និងខ្ញុំបានគិតថា វេជ្ជបណ្ឌិតប្រចាំគ្រួសារ និងគ្រូពេទ្យសរសៃប្រសាត មិនបានប្រាប់យើងអំពីការពិតទាំងអស់នោះទេ។ សរុបមក ពួកគេបានដាក់ខ្ញុំដាច់ឡែក ដោយប្រាប់ថា: តាមដានភាពធ្ងន់ធ្ងរនៃជំងឺដែលបានកើតមានចំពោះខ្ញុំ។

បន្ទាប់មក វេជ្ជបណ្ឌិតបានដាក់ខ្ញុំនៅក្នុងបន្ទប់មួយតូច ដែលមានទំហំប៉ុន្មានម៉ែត្របួនជ្រុងប៉ុណ្ណោះ ជាបន្ទប់មួយដាច់ឡែកតែឯង។ ក្រុមគ្រូពេទ្យត្រូវពាក់ម៉ាស់ និងស្រោមដៃ នៅពេលដែលចូលមកមើលខ្ញុំ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំដូចជាកំពុងផ្ទុកនូវវិទ្យុសកម្ម។

ខ្ញុំនៅម្នាក់ឯងជាច្រើនម៉ោង ដូច្នេះខ្ញុំបានប្រើពេលវេលាដ៏សំខាន់នេះ ទូលសុំយ៉ាងទទូចដល់ព្រះយេស៊ូ ជាព្រះសង្គ្រោះរបស់ខ្ញុំ សូមឲ្យព្រះអង្គប្រោសខ្ញុំ។ ពេលនោះ ខ្ញុំក៏មានចិត្តសុខសាន្ត មិនថាមានអ្វីបានកើតឡើងនៅជុំវិញខ្ញុំឡើយ។

ប៉ុន្មានថ្ងៃក្រោយមក ពួកគេបាននាំខ្ញុំទៅកាន់សេវាកម្មមួយផ្សេងទៀត ហើយបានដាក់ខ្ញុំនៅក្នុងបន្ទប់ផ្នែកសរសៃប្រសាទ ហើយជាចៃដន្យ មានវេជ្ជបណ្ឌិតម្នាក់ ដែលខ្ញុំបានស្គាល់តាមរយៈការងាររបស់ខ្ញុំ។ គាត់បានមើលថែខ្ញុំយ៉ាងល្អ ហើយបានពន្យល់អំពីគ្រប់ទាំងការព្យាបាលដែលខ្ញុំបានឆ្លងកាត់ និងអំពីគុណប្រយោជន៍នៃការព្យាបាលទាំងនោះ។ គាត់មិនបានលាក់ការបារម្ភរបស់គាត់ អំពី

ពេគវិនិច្ឆ័យដែលបានរកឃើញនោះទេ ពីព្រោះមានចំណុចច្រើនមិនទាន់ច្បាស់សោះ។

ប៉ុន្តែ ច្រើនថ្ងៃកន្លងមកនេះ គ្រួសារខ្ញុំ និងគ្រិស្តបរិស័ទជាច្រើនបានអធិស្ឋានឲ្យខ្ញុំ។

នៅក្នុងបន្ទប់ដែលគេដាក់ខ្ញុំ ខ្ញុំបានសះស្បើយឡើងៗ ហើយក្រុមគ្រូពេទ្យបានឆ្ងល់ដែលឃើញខ្ញុំជាសះស្បើយយ៉ាងឆាប់រហ័សបែបនេះ។ ក្រោយពីការលេបថ្នាំពីរសប្តាហ៍ ខ្ញុំមានអារម្មណ៍ល្អឡើងវិញ គឺដូចជាគ្មានអ្វីបានកើតឡើងសោះ ហើយខ្ញុំ និងក្រុមគ្រួសាររបស់ខ្ញុំដែរ បានដឹងថា ព្រះអម្ចាស់បានប្រោសខ្ញុំឲ្យជាសះស្បើយទាំងស្រុង។

ប៉ុន្តែ វេជ្ជបណ្ឌិតមិនចង់ឲ្យខ្ញុំចេញពីមន្ទីរពេទ្យទេ។ គាត់បានជំរុញឲ្យខ្ញុំទៅអូស្ត្រាលី ដើម្បីធ្វើម៉ាស៊ីនរលកសំឡេងរូបភាពម៉ាញ៉េទិក (MRI) ដើម្បីឲ្យប្រាកដថាគ្មានផលប៉ះពាល់ ហើយឲ្យប្រាកដថា ខ្ញុំពិតជាបានជាសះស្បើយទាំងស្រុងមែន ឬយ៉ាងណា។ ទាំងប្រពន្ធខ្ញុំ និងខ្ញុំមិនចង់ទៅទេ ដោយជឿច្បាស់ថា នេះជាការជាសះស្បើយទាំងស្រុង ប៉ុន្តែវេជ្ជបណ្ឌិតបានទទូច ហើយមិនបានឲ្យជម្រើសយើងឡើយ។

ដូច្នេះ ប៉ុន្មានថ្ងៃក្រោយមក យើងបានធ្វើដំណើរតាមយន្តហោះទៅប្រទេសអូស្ត្រាលី ហើយបានទទួលយកការពិនិត្យទាំងអស់។ បន្ទាប់មក យើងគ្មានការភ្ញាក់ផ្អើលទេ នៅពេលដែលសាស្ត្រាចារ្យបានអានលទ្ធផល MRI ឲ្យយើងស្តាប់នៅក្នុងការិយាល័យរបស់គាត់ ដែលបានប្រកាសថា គ្មានសញ្ញានៃជំងឺរលាកស្រោមខួរទៀតទេ ហើយក៏គ្មានផលប៉ះពាល់ដែរ។ ពាក្យសម្តីរបស់គាត់ មិនបានធ្វើឲ្យយើងភ្ញាក់ផ្អើលទេ ដោយព្រោះយើងបានដឹងនៅក្នុងជម្រៅចិត្តរបស់យើងរួចហើយថា ព្រះជាម្ចាស់បានដោះខ្ញុំឲ្យរួចទាំងស្រុងហើយ។ ការមួយដែលខ្ញុំចង់ធ្វើ ក្នុងកាលដែលខ្ញុំកំពុងអង្គុយនៅក្នុងការិយាល័យ គឺស្រែកថា៖ "អរព្រះគុណ

*ព្រះអម្ចាស់... ព្រះអង្គល្អណាស់!"។*

*នេះហើយជារបៀបដែលយើងអាចទទួលបានការរំដោះឲ្យរួច សូម្បីតែជំងឺរោគារបស់យើង។ ប្រសិនបើលោកអ្នកទុកចិត្តព្រះអង្គ ហើយទូលសុំព្រះអង្គដោយជឿច្បាស់ថា ព្រះអង្គស្តាប់ ហើយជឿច្បាស់ថា ព្រះអង្គពិតជាចង់ឲ្យយើងជា ពិតជាចង់ឲ្យយើងមានខុសភាពល្អ នោះលោកអ្នកមានចម្លើយជាពិត។*

*ប្រសិនបើព្រះជាម្ចាស់អនុញ្ញាតតទៅប់ៗនេះ ខ្ញុំនឹងចែកចាយនៅក្នុងសៀវភៅមួយទៀត អំពីរបៀបដែលព្រះជាម្ចាស់បានប្រោសកូនស្រីរបស់ខ្ញុំឲ្យមានជីវិតឡើងវិញ នៅពេលដែលនាងកំពុងស្លាប់ក្នុងដៃរបស់ខ្ញុំ។ មានការអស្ចារ្យជាច្រើនផ្សេងទៀត និងការប្រោសឲ្យជាជាចម្រើនដែលមកពីព្រះ។*

*ចុងបញ្ចប់ជាមួយគ្នានេះ ខ្ញុំចង់ឲ្យលោកអ្នកទូលទៅព្រះជាម្ចាស់យ៉ាងសាមញ្ញដូចដែលខ្ញុំនឹងបង្ហាញលោកអ្នក។*

*ថ្ងៃនេះ ប្រសិនបើលោកអ្នកកំពុងរងទុក្ខ ជាប់ចំណងនៃសេចក្ដីស្រើបស្រាល និងអបាយមុខ ដែលអាចជាថ្នាំញៀន ស្រា ការរួមភេទជាមួយមនុស្សភេទដូចគ្នា ពេស្យាចារ្យ ឬជាចំណងណាមួយផ្សេងទៀតក៏ដោយ។ ខ្ញុំសូមអញ្ជើញលោកអ្នកឲ្យងាកមករកព្រះយេស៊ូ រឿងនេះសាមញ្ញទេ គឺដូចដែលខ្ញុំបានធ្វើកាលខ្ញុំឆ្លងកាត់ពេលវេលាដ៏ខ្មៅងងឹតដូច្នោះដែរ។ លោកអ្នកយាងព្រះអង្គឲ្យជួយលោកអ្នកថ្វាយចិត្តដល់ព្រះអង្គ សូមឲ្យព្រះអង្គអត់ទោសលោកអ្នក ពីគ្រប់ទាំងអំពើបាបដែលបានបំបែកលោកអ្នកចេញពីសេចក្ដីស្រឡាញ់របស់ព្រះអង្គ និងពីព្រះវត្តមានរបស់ព្រះអង្គ។*

*ខ្ញុំអាចប្រាប់លោកអ្នកបានជាប្រាកដថា ព្រះយេស៊ូនឹងផ្លាស់ប្រែជីវិតទាំងមូលរបស់លោកអ្នក។*

*សូមនិយាយថា៖ "**ព្រះជាម្ចាស់ដែលប្រកបដោយព្រះហឫទ័យមេត្តាករុណា ព្រះ***

***យេស៊ូ ព្រះសង្គ្រោះរបស់ទូលបង្គំ សូមយាងមក ហើយជួយទូលបង្គំផង។ ដ្បិតព្រះអង្គស្គាល់ទូលបង្គំច្បាស់ ព្រោះព្រះអង្គបានបង្កើតទូលបង្គំមក។ ព្រះអង្គស្គាល់ពីសេចក្ដីវេទនារបស់ទូលបង្គំ ដូច្នេះសូមយាងមក ហើយដោះទូលបង្គំឲ្យរួចពីអ្វីៗដែលចងទូលបង្គំ ហើយបំបែកទូលបង្គំចេញឆ្ងាយពីព្រះអង្គ។ សូមកែទូលបង្គំឲ្យបានកើតជាថ្មី សូមអត់ទោសទូលបង្គំពីអំពើបាប ហើយសូមដឹកនាំទូលបង្គំអស់មួយជីវិតទូលបង្គំផង។ អាម៉ែន"។***

*ខ្ញុំចង់បញ្ចប់សៀវភៅនេះ ដោយថ្វាយគ្រប់ទាំងសិរីរុងរឿងដល់ព្រះជាម្ចាស់របស់ខ្ញុំ ជាព្រះជាម្ចាស់ដែលគង់នៅអស់កល្ប ហើយជាព្រះដែលសង្គ្រោះខ្ញុំ។ ចូរយើងនឹកចាំជានិច្ចថា ព្រះអង្គបានចាត់ព្រះរាជបុត្រាតែមួយរបស់ព្រះអង្គ ឲ្យយាងមកដើម្បីឲ្យយើងអាចមានជីវិត។ អ្វីៗដែលខ្ញុំបានសរសេរនេះ នឹងមិនកើតឡើងឡើយ ប្រសិនបើខ្ញុំមិនបានស្គាល់ព្រះយេស៊ូ។ សព្វថ្ងៃនេះ ខ្ញុំជាមនុស្សម្នាក់រីករាយ ខ្ញុំទទួលបទពិសោធន៍នៃការកើតជាថ្មីនេះ ដូចដែលខ្ញុំបានប្រាប់លោកអ្នកពីខាងដើមរួចហើយ ហើយខ្ញុំបម្រើព្រះអម្ចាស់ ដោយអំណរដ៏ពោរពេញ។*

*ពិតមែនហើយ យើងរាល់គ្នាឆ្លងកាត់ពេលវេលាដ៏លំបាក ដ្បិតយើងកំពុងរស់នៅលើផែនដីនេះ ដែលពោរពេញទៅដោយភាពអយុត្តិធម៌ និងបញ្ហាជាច្រើន ប៉ុន្តែសេចក្ដីសុខសាន្តដែលព្រះយេស៊ូប្រទានឲ្យ គឺជាសុភមង្គលដ៏ពិតដែលយើងអាចស្គាល់បាន ហើយជាការធានាដែលយើងមាន ដែលថា ព្រះអម្ចាស់ដ៏មានព្រះចេស្ដា ទ្រង់តែងជួយជានិច្ច។ នោះហើយជាការធានានៃជីវិតមួយដ៏អស្ចារ្យ ដល់អស់អ្នកណាដែលទទួលព្រះអង្គ។*

***“ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម៉្លេះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ” (យ៉ូហាន ៣:១៦)។***

***“យើងខ្ញុំអង្វរគេជំនួសព្រះគ្រិស្តថា ចូរឲ្យបានជាមេត្រីនឹងព្រះចុះ”***
*២កូរិនថូស ៥:២០*

*ទីបន្ទាល់របស់ខ្ញុំចប់ត្រឹមប៉ុណ្ណេះ។*

_*_*_*_*_*_*_*_*_*_*_*_*_*_*_*_*_*_

*ប្រសិនបើលោកអ្នកចង់សួរខ្ញុំ ហើយបើខ្ញុំអាចជួយបាន និងប្រសិនបើលោកអ្នកចង់ជួបគ្រិស្តបរិស័ទឯទៀតៗ ឬចង់បានពត៌មានលម្អិតអំពីក្រុមជំនុំរបស់យើង សូមទាក់ទងមកខ្ញុំដោយរីករាយតាមរយៈ*

E-mail: william@temoignagewilliam.com

*ឬតាមអាសយដ្ឋាន:* William THERON BP 14514 98803 Nouméa Nouvelle Calédonie.

Website: www.temoignagewilliam.com

*ក្រុមជំនុំរបស់ខ្ញុំឈ្មោះ Eglise évangélique Nouméa Nouvelle Calédonie.*

*លោកអ្នកអាចចង់មិត្ត តាមរយៈគេហទំព័រ* Facebook
https://www.facebook.com/william.theron.7
*ដោយ* Add Friend *ដើម្បីយើងអាចចែកចាយពីការដ៏អស្ចារ្យរបស់ព្រះ។*

*សូមទាញយកសំណៅភាសាអង់គ្លេស អមជាមួយរូបភាពដោយឥតគិតថ្លៃ តាមរយៈ*
http://pdf.lu/30wb

*សូមអរគុណដល់អស់លោកអ្នកអ្នក ដែលបានជួយខ្ញុំបន្តកិច្ចការនេះឲ្យដំណើរការទៅបាន។ ជាមួយនឹងការជួយផ្តល់គំនិតដ៏មានតម្លៃ និងការជ្រោមជ្រែង ក៏ដូចជាការអធិស្ឋានរបស់អ្នកទាំងនោះ ដែលពួកគេបានរួមចំណែកនៅក្នុងភាពជោគជ័យនៃទីបន្ទាល់ជាសំណេរនេះ។ ជាងនេះទៅទៀត ប្រាកដណាស់ សូមថ្វាយគ្រប់ទាំងសិរីរុងរឿងដល់ព្រះអម្ចាស់យេស៊ូ ជាព្រះសង្គ្រោះរបស់យើង។*

*****



ខ្ញុំកើតនៅថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ១៩៦៤ នៅរដ្ឋ Valenciennes ភាគខាងជើងនៃប្រទេសបារាំង។ នេះជារឿងរ៉ាវនៃទុក្ខលំបាក ដែលមាននៅក្នុងវ័យកុមារភាពដ៏ឈឺចាប់របស់ខ្ញុំ ដែលស្ថិតក្នុងគ្រួសារមួយពេញដោយអំពើហិង្សាជារៀងរាល់ថ្ងៃ។ ម្ដាយរបស់ខ្ញុំទទួលរងការវាយដំ រួមទាំងខ្ញុំផងដែរ។

ម្ដាយរបស់ខ្ញុំបានរត់ចេញពីផ្ទះជាមួយកូនបីនាក់។ ពួកយើងរស់នៅក្នុងស្ថានភាពក្រីក្រ ហើយនេះជាពេលវេលាមួយដ៏ឈឺចាប់នៅក្នុងជីវិតរបស់យើង។

នៅពេលជាក្មេងជំទង់ម្នាក់ ខ្ញុំបានខិតខំធ្វើការធ្វើ ដើម្បីរកលុយមកផ្ទះ។ ដោយការតស៊ូ និងសេចក្ដីក្លាហាន ខ្ញុំបានទទួលជោគជ័យក្នុងមុខជំនួញយ៉ាងឆាប់រហ័ស ប៉ុន្តែខ្ញុំបានជួបប្រទះភាពទ្រុឌទ្រោម និងក្ស័យធន ហើយធ្លាក់ចូលទៅក្នុងទ្វាររក។

គោលបំណងនៃសៀវភៅនេះ គឺនាំសេចក្ដីសង្ឃឹមដល់អស់លោកអ្នកដែលជួបលំបាកក្នុងជីវិត ហើយចង់បានការផ្លាស់ប្រែមួយដ៏ពិតប្រាកដ។

សូមអានដោយរីករាយ

វីល្យាម ធេរ៉ុន (William THERON)